**សកម្មភាព** ៖ **ល្បែងអារម្មណ៍**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

**សិក្សាសង្គម**

ការយល់ដឹងអំពីខ្លួនឯង(ស្គាល់ពីអារម្មណ៍មួយចំនួន)

(សម្តែងអារម្មណ៍ និងចេះសង្កត់ចិត្តរបស់ខ្លួន)

**ភាសាខ្មែរ**

ការស្តាប់ (ស្តាប់គេនិយាយ និងមានសម្ថភាពស្តាប់ដោយធ្វើតាមការណែនាំងាយៗ)។

**គោលបំណង**

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

**(សិក្សាសង្គម)** ប្រាប់បានពីអារម្មណ៍ ឬឥរិយាបថនៃការព្រួយបារម្មណ៍ កង្វល់ក្នុងព្រឹត្តិការណ៍មួយចំនួន។ ប្រាប់បានពីអារម្មណ៍របស់ខ្លួននៅពេលជួបរឿងមិនសប្បាយចិត្ត និងសប្បាយចិត្តដោយការធ្វើកាយវិការ ទឹកមុខ និងពាក្យសម្តី។

**(ភាសាខ្មែរ)** ប្រាប់ឡើងវិញពីសកម្មភាពតាមដំណាក់កាល ដោយអនុវត្តតាមដំណាក់កាលណែនាំ។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង “បិសាចចម្លែកតូចៗ” ។

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ សៀវភៅរឿង “បិសាចចម្លែកតូចៗ” ។

**ការរៀបចំ** ៖ អានសៀវភៅរឿង “បិសាចចម្លែកតូចៗ” ឱ្យបានស្ទាត់ ។

**សេក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងអានរឿង “បិសាចចម្លែកតូចៗ” ឱ្យកូនៗទាំងអស់គ្នាស្តាប់។
2. ហើយយើងនឹងលេង**ល្បែងអារម្មណ៍** ដែលដកស្រង់ចេញពីរឿងនេះ។
3. សួរក្មេងៗ៖ តើសាច់រឿងដំបូងទឹកមុខរបស់តួរអង្គ(មករា) យ៉ាងម៉េចដែរ? មករាបានយំ។
   តើតួរអង្គដំបូងកំពុងបង្ហាញអារម្មណ៍មួយណា? អារម្មណ៍ភ័យខ្លាច។ ។

4. ឱ្យក្មេងៗទាំងអស់បង្ហាញអារម្មណ៍(យំ)តាមតួអង្គ(មករា)។
5. និយាយពីពេលវេលានៅពេលដែលមករាបានបង្ហាញអារម្មណ៍នោះនៅក្នុងទំព័រទី៣៖ តួអង្គ(មករា)យល់សបិន្តឃើញរឿងអាក្រក់ណាស់នៅពេលយប់មានបិសាចចម្លែកតូចៗ រាប់ពាន់ រាប់លានក្បាល! ពួកវាចង់ធ្វើបាបមករា។ វាបានព្យាយាមចូលក្នុងមាត់ និងច្រមុះរបស់មករា។ ដូចនេះទើបតួអង្គ(មករា)យំ ហើយមានអារម្មណ៍ភ័យខ្លាច។
6. អានទំព័រទី៦ឱ្យក្មេងៗស្តាប់ម្តងទៀត ៖ រតនានិយាយទាំងញញឹម៖ អ៊ូ... មែនហើយ! វាជាបិ សាច។ គេហៅពួកវាថា "មេរោគ" ។ ត្រូវហើយមករា ។ ពួកវាមានរូបរាងតូចៗ មិនអាចមើលវាឃើញដោយ ភ្នែកទទេបានឡើយ ហើយវាអាក្រក់ខ្លាំណាស់។ ពួកវារស់នៅគ្រប់ទីកន្លែង។ រតនានិយាយទាំងចាក់ ក្រឡេក ប្អូន៖ នៅទីនេះ! នៅទីនោះៗ! នៅទីនេះៗ! នាងចាក់ ក្រឡេក មករា រហូតធ្វើឲ្យគាត់ស្រែក និងសើចខ្លាំងៗ។ ពន្យល់ថានេះជាចំណុចដែល តួអង្គ(មករា)ត្រូវសើច។
7. សួរក្មេងៗថា៖ តើនៅពេលណាដែលកូនៗបង្ហាញអារម្មណ៍ភ័យខ្លាច? (ជួបហេតុការណ៍មិនល្អ ) ឱ្យក្មេងៗឆ្លើយ បង្ហាញអារម្មណ៍ឧទាហរណ៍៖ លាងដៃមិនស្អាត ប្រលាក់មេរោគ ដើរដួល រត់ដួល។ តើនៅពេលណាដែលកូនៗបង្ហាញអារម្មណ៍សើចសប្បាយ? (ជួបហេតុការល្អ) ឱ្យក្មេងៗឆ្លើយ បង្ហាញអារម្មណ៍ឧទាហរណ៍៖ រៀនបានពិន្ទុខ្ពស់ លាងបានដៃស្អាត ។

**បំរែបំរួល៖**

តាមស្ថានភាពរបស់សាច់រឿងនីមួយៗ មានអារម្មណ៍ជាច្រើនដែលអាចលេងបាន។

ឧទាហរណ៍៖ យំ ស្រែក សើច ពេប ញញឹម ...។